UNITED NATIONS
HUMAN RIGHTS
SPECIAL PROCEDURES
SPECIAL RAPPORTEURS, INDEPENDENT EXPERTS & WORKING GROUPS

# គោលការណ៍ណែនាំទាក់ទងនឹងមេរោគឆ្លងកូវីដ-១៩[1]
# ស្តីពី
# ការការពារអ្នកដែលកំពុងរស់នៅដោយគ្មានផ្ទះសម្បែង


**លោកស្រី ឡីឡានី ហ្វាហា**

**អ្នករាយការណ៍ពិសេស ស្តីពីសិទ្ធិមានលំនៅឋានសមរម្យ**


**បានធ្វើបច្ចុប្បន្នភាព ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២០**

លំនៅឋាន បានក្លាយជាទីកន្លែងការការពារជួរមុខប្រឆាំងនឹងមេរោគកូរ៉ូណា ហើយលំនៅឋានក៏បានក្លាយជាស្ថានភាពស្លាប់រស់កាន់តែខ្លាំងឡើង។

រដ្ឋាភិបាលនៅទូទាំងសាកលលោក បានប្រើគោលនយោបាយ "នៅផ្ទះ" "ដាក់ខ្លួននៅដាច់តែឯង" "រក្សាគម្លាតពីគ្នា" និង "លាងសម្អាតដៃរបស់អ្នក" ដើម្បីធ្វើឲ្យនិន្នាការនៃការរីករាលដាលមេរោគថយចុះទាប និងដើម្បីកាត់បន្ថយអត្រាឆ្លងនៃមេរោគកូរ៉ូណា។ គោលនយោបាយទាំងនេះ ត្រូវបានកំណត់ឡើងដោយសន្មត់ថា មនុស្សគ្រប់រូប មានផ្ទះសម្បែងដែលមានសេវាអនាម័យគ្រប់គ្រាន់។ ប៉ុន្តែវាមិនមែនជាករណី សម្រាប់ប្រជាជន ៨០០លាននាក់ ឬប្រហាក់ប្រហែលនេះ ដែលកំពុងរស់នៅដោយគ្មានផ្ទះសម្បែងក្នុងសកលលោកនេះទេ។ លើសពីនេះទៀត ប្រជាជនដែលមានហានិភ័យខ្ពស់ផ្នែកសុខភាព ក៏ជួបប្រទះបញ្ហាប្រឈមផ្នែកសុខភាពដែលមិនមានលក្ខណៈសមាមាត្រ និង អត្រាខ្ពស់នៃជំងឺផ្លូវដង្ហើម ដែលជម្រុញឲ្យពួកគេកាន់តែងាយប្រឈមឆ្លងមេរោគនេះ និងមេរោគថ្មីៗ។

នៅចំពោះមុខនៃការរីករាលដាលនៃមេរោគឆ្លងនេះ កង្វះខាតការទទួលបានលំនៅឋានសមរម្យ គឺដូចគ្នានឹងការដាក់ទោសប្រហារជីវិតដែលនឹងត្រូវធ្វើឡើងចំពោះប្រជាជនដែលកំពុងរស់នៅដោយគ្មានផ្ទះ

---

[1] គោលការណ៍ណែនាំនេះ បានត្រូវធ្វើឡើងតាមរយៈកិច្ចពិគ្រោះយោបល់ជាមួយអ្នកតស៊ូមតិមកពី អាស៊ី អាហ្វ្រិក អឺរ៉ុប អាមេរិកខាងជើង និងអាមេរិកឡាទីន។ គោលការណ៍ណែនាំនេះ អាចត្រូវធ្វើបច្ចុប្បន្នភាពជាបន្តទៀតដោយបញ្ចូលនូវដំបូន្មានរបស់អ្នកជំនាញការការអនុវត្តល្អៗ ឬមេរៀនបទពិសោធន៍ ។

សម្បែង និងដាក់ប្រជាជនក្នុងចំនួនកាន់តែច្រើនថែមទៀតនៅក្នុងហានិភ័យជាបន្ត។ កូវីដ-១៩ បានស្តែងឲ្យឃើញ ពីគំនិតអាត្មានិយម ដោយបង្ហាញតាមរបៀបដែលសុខមាលភាពទូទៅរបស់យើងមិនត្រឹមតែពឹងលើលទ្ធភាពផ្ទាល់ខ្លួនរបស់យើងដោយ "នៅផ្ទះ" តែប៉ុណ្ណោះទេ គឺលទ្ធភាពរបស់អ្នកដទៃទៀតដែលត្រូវធ្វើឡើងដូចគ្នា។

ភាពគ្មានផ្ទះសម្បែង ដែលរាប់បញ្ចូលទាំងអំឡុងពេលមានវិបត្តិ និងដោយមិនគិតទៅដល់សញ្ជាតិ ឬឋានៈផ្លូវច្បាប់របស់បុគ្គល គឺជាការរំលោភសិទ្ធិមនុស្សតាមព្រឹត្តិហេតុ។ ការការពារចម្បងដែលផ្តល់អោយតាមរយៈសិទ្ធិមានលំនៅឋាន ក៏ដូចជាសិទ្ធិខាងសុខភាព និងសិទ្ធិមានម្ហូបអាហារ គឺជាមូលដ្ឋានគ្រឹះនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស និងការថែរក្សាជីវិត ដែលសិទ្ធិទាំងនេះមិនអាចត្រូវបានគេបង្អាក់សោះឡើយ ទោះបីជាស្ថិតនៅក្នុងស្ថានភាពនៃការដាក់ប្រទេសក្នុងគ្រាអាសន្នក៏ដោយ។

នៅក្នុងបរិបទនេះ រដ្ឋទាំងឡាយ ត្រូវតែដោះស្រាយនូវតម្រូវការលំនៅឋានរបស់ប្រជាជនដែលគ្មានផ្ទះសម្បែងជាបន្ទាន់ និងដោយអាទិភាព ដើម្បីធានាឲ្យមានការការពារស្មើគ្នាប្រឆាំងនឹងមេរោគឆ្លង និងការការពារចំពោះប្រជាជនទូទៅ។ កិច្ចការនេះ ទាមទារឲ្យមានការសហការរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីមានធនធានចាំបាច់ និងមានសមត្ថភាពដែលធានាបានថាកិច្ចប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃមេរោគនេះអនុវត្តដោយប្រសិទ្ធភាព។ រដ្ឋទាំងឡាយដោយប្រកាន់ខ្ជាប់នូវកាតព្វកិច្ចសិទ្ធិមនុស្សរបស់ខ្លួន ត្រូវតែចាត់វិធានការបន្ទាន់ នានាដូចខាងក្រោម៖

១. ផ្តល់ភ្លាមៗនូវទីកន្លែងស្នាក់នៅដល់ប្រជាជនគ្មានផ្ទះសម្បែងទាំងអស់ដែលកំពុងរស់នៅ "យ៉ាងលំបាក" ឬរស់នៅតាមដងផ្លូវ ទន្ទឹមគ្នានេះដែរគិតគូរពីការផ្ទេរពួកគេអោយទៅរស់នៅលំនៅឋានអចិន្ត្រៃយ៍ដើម្បីពួកគេមិនវិលត្រឡប់មករស់នៅក្នុងស្ថានភាពគ្មានផ្ទះសម្បែងវិញនៅពេលបញ្ចប់នៃការរីករាលដាលនៃមេរោគនេះ។ ការណ៍នេះ អាចតម្រូវឲ្យមានការស្វះស្វែងរកបន្ទប់តាមសណ្ឋាគារឬ ម៉ូតែល ឬសម្រួលគោលដៅនៃការប្រើប្រាស់ទីតាំងអគារឡើងវិញ ដូចជា បន្ទាយកងទ័ព ឬមន្ទីរពេទ្យដែលគេមិនប្រើប្រាស់។ អាជ្ញាធរសាធារណៈ គួរត្រូវបានផ្តល់អំណាចដើម្បីរៀបចំប្រើប្រាស់[2]នូវលំនៅឋានទំនេរ ឬផ្ទះបណ្តោះអាសន្នដែលបានកាន់កាប់ជាលក្ខណៈឯកជន។

---

[2] "ការកាត់បន្ថយជាបណ្តោះអាសន្ននូវសិទ្ធិកាន់កាប់លំនៅឋានលក្ខណៈបណ្តោះអាសន្ន ឬទំនេរនេះ ដែលតាមអត្ថន័យនេះ គឺជាការធ្វើឡើងដោយមិនមានផលប៉ះពាល់ណាមួយលើសិទ្ធិមានលំនៅឋានរបស់ម្ចាស់ផ្ទះទាំងនោះឡើយ។ កំណត់សម្គាល់នេះ ត្រូវបានបន្ថែមដោយការិយាល័យOHCHRប្រចាំកម្ពុជា។"

២. ធានាថា ស្ត្រី កុមារ និងយុវជនដែលអាចមានតម្រូវការចាកចេញពីផ្ទះសម្បែងដោយសារអំពើហិង្សានឹងមិនធ្លាក់ចូលក្នុងស្ថានភាពគ្មានផ្ទះសម្បែងឡើយ និងត្រូវបានផ្តល់ឲ្យនូវទីកន្លែងស្នាក់នៅជំនួសដែលសមរម្យ ដែលធានាសុវត្ថិភាព និងផ្តល់នូវការទទួលបាន ទឹក/អនាម័យ ម្ហូបអាហារ ការគាំពារផ្នែកសង្គម សេវាសុខភាព និងការធ្វើតេស្តរកមេរោគកូវីដ-១៩។

៣. ធានាថា ទីកន្លែងស្នាក់នៅគ្រាអាសន្ន មាននូវស្ថានភាពដែលរក្សាគម្លាតពីគ្នា ដាក់ខ្លួននៅដាច់តែឯងចត្តាឡីស័ក និងស្របតាមអនុសាសន៍នានាអំពីសុខភាព ដែលចេញដោយអង្គការសុខភាព ពិភពលោក ដើម្បីបញ្ឈប់ការរីករាលដាលនៃមេរោគកូវីដ-១៩។ អ្នករស់នៅតាមទីកន្លែងទាំងនោះត្រូវតែមាននូវសិទ្ធិឯកជនភាព ទឹក/អនាម័យ ម្ហូបអាហារ ការគាំពារផ្នែកសង្គម និងផ្លូវចិត្ត សេវា សុខភាព និងការធ្វើតេស្តរកមេរោគកូវីដ-១៩។ ការយកចិត្តទុកដាក់ជាពិសេស គួរត្រូវបានគេធ្វើឡើង ដើម្បីធានាឲ្យមានការផ្តល់នូវលំនៅឋានសមរម្យសម្រាប់គ្រួសារទាំងឡាយដែលកំពុងរស់នៅដោយគ្មានផ្ទះសម្បែងសម្រាប់ស្ត្រី និងកុមារ បុគ្គលមានពិការភាពផ្នែករាងកាយ ឬផ្នែកសង្គម-ចិត្តសាស្ត្រ និងជនដែលឋិតនៅក្នុងហានិភ័យជាក់លាក់ (អាយុលើស ៦0 ឆ្នាំ ឬលក្ខខណ្ឌ សុខភាពមានបញ្ហាស្រាប់ពីមុនមក)។ ការបំបែកកុមារចេញពីអាណាព្យាបាល ឬសមាជិកគ្រួសារដែលកំពុងគាំទ្រដល់ពួកគាត់ត្រូវតែជៀសវាងជានិច្ច ទោះនៅក្នុងពេលនៃការដាក់ខ្លួនដាច់តែឯងរបស់សមាជិកគ្រួសារណាម្នាក់ក្នុងបន្ទប់ដាច់ដោយឡែកដែលត្រូវបានតម្រូវសម្រាប់ការគ្រប់គ្រង មេរោគក៏ដោយ។

៤. នៅទីណាដែលអាចធ្វើបាន និងសមស្រប រដ្ឋាភិបាល គួរទិញបន្ទប់លក្ខណៈលំនៅឋានសម្រាប់ប្រើប្រាស់រយៈពេលខ្លី និងវែង ដើម្បីធានាថា ប្រជាជនគ្មានផ្ទះសម្បែង ត្រូវបានផ្តល់ផ្ទះឲ្យរស់នៅក្នុងអំឡុងពេល និងក្រោយពេលនៃការរីករាលដាលនៃមេរោគនេះ ហើយដែលជាមធ្យោបាយមួយនៃការបង្កើនទ្រព្យសាធារណៈរបស់ខ្លួន។

៥. ធានាថា មនុស្សគ្រប់រូបដែលកំពុងរស់នៅគ្មានផ្ទះសម្បែង ដោយមិនគិតពីទីកន្លែងដែលពួកគេកំពុងរស់នៅ ទទួលបានការថែរក្សាសុខភាពដោយឥតគិតថ្លៃ និងការធ្វើតេស្តដោយមិនរើសអើង។ ត្រូវតែមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយនូវព័ត៌មានដែលទទួលបាន និងព័ត៌មានបច្ចុប្បន្នភាពស្តីពីកូវីដ-១៩ រួមទាំងការអនុវត្តការថែទាំសុខភាពឲ្យល្អបំផុត គោលនយោបាយសុខភាពរបស់រដ្ឋាភិបាល និងអំពីទីកន្លែង និងរបៀបដែលសេវាថែទាំសុខភាពអាចរកបាន។

៦. ធានាឲ្យមាននូវបង្គន់សាធារណៈ បន្ទប់ងូតទឹកសាធារណៈ និងសម្ភារបរិក្ខារ និងផលិតផលលាងសម្អាតដៃសម្រាប់បុគ្គលគ្មានផ្ទះសម្បែងដែលរស់នៅតាមដងផ្លូវដែលគ្មានលទ្ធភាពប្រើប្រាស់

សម្ភារបរិក្ខារបែបឯកជន។ សម្ភារបរិក្ខារទាំងនេះ ត្រូវតែមានការថែទាំត្រឹមត្រូវ ដោយមានទឹកស្អាត និងសាប៊ូនៅនឹងកន្លែងគ្រប់ពេលវេលា និងត្រូវតែមានការសម្អាតសម្លាប់មេរោគជាទៀតទាត់។

៧. ផ្តល់ឲ្យបុគ្គលគ្មានផ្ទះសម្បែងដែលមានរោគសញ្ញាមេរោគ និងអ្នកដែលធ្វើតេស្តមានលទ្ធផលវិជ្ជមានមេរោគកូរ៉ូណានូវទីកន្លែងដែលមានសុវត្ថិភាពដើម្បីស្នាក់នៅ ការយកចិត្តទុកដាក់ព្យាបាលភ្លាមៗ ការទទួលបានម្ហូបអាហារ និងឱសថចាំបាច់នានា និងការគាំពារផ្សេងៗ ដើម្បីធានាថា ពួកគេអាចគ្រប់គ្រងជួយខ្លួនឯងបានក្នុងពេលចត្តាឡីស័ក ឬការដាក់ខ្លួននៅដាច់តែឯង។

៨. ធានាថា ប្រជាជនរស់នៅដោយគ្មានផ្ទះសម្បែង មិនត្រូវបានដាក់ឲ្យជាប់ពីបទព្រហ្មទណ្ឌ ពិន័យជាប្រាក់ ឬ ដាក់ទណ្ឌកម្ម ក្នុងការអនុវត្តបម្រាមគោចរណ៍ ឬវិធានការបង្ខាំងនានា និងបញ្ឈប់ការអនុវត្តនូវច្បាប់ដែលបង្កើនដល់ការផាត់ចេញចំពោះប្រជាជនដែលកំពុងស្ថិតក្នុងភាពគ្មានផ្ទះសម្បែង រួមទាំងការដកហូតទ្រព្យសម្បត្តិបុគ្គល ឬ “ការបោសសម្អាត” មនុស្សរស់នៅតាមដងផ្លូវ។

៩. បញ្ឈប់ការបណ្តេញចេញដោយបង្ខំ ឬការរុះរើទីតាំងរស់នៅលក្ខណៈមិនរៀបរយរបស់ប្រជាជនគ្មានផ្ទះសម្បែង និងទទួលស្គាល់ថា នៅក្នុងកាលៈទេសៈខ្លះ ទីតាំងទាំងនេះ អាចជាកន្លែងដែលមានសុវត្ថិភាពជាងកន្លែងស្នាក់នៅផ្សេងៗ ដូចជាជម្រករៀបចំជាបណ្តោះអាសន្ន។ ទោះជាយ៉ាងណាក៏ដោយ អ្នករស់នៅក្នុងទីតាំងមិនរៀបរយទាំងនោះត្រូវតែបានគេផ្តល់ឲ្យនូវជម្រើសសម្រាប់ការផ្លាស់ទៅស្នាក់នៅកន្លែងជំនួសផ្សេង ជាទីកន្លែងដែលការដាក់ខ្លួននៅដាច់តែឯងអាចធ្វើទៅបាន។ [សម្រាប់អនុសាសន៍បន្ថែមនានាទាក់ទងនឹងទីតាំងរស់នៅមានលក្ខណៈមិនរៀបរយ សូមមើល គោលការណ៍ណែនាំទាក់ទងនឹងជំងឺឆ្លងកូវីដ-១៩ ស្តីពីការការពារអ្នករស់នៅតាមសំណង់មិនរៀបរយ]។

១០. ជម្រកស្នាក់នៅគ្រាអាសន្នដែលបំពាក់សម្ភារបរិក្ខារអនាម័យ និងសាលគ្រែដេកសម្រាប់ប្រើប្រាស់រួម បើទោះបីជាគ្រែដេកសម្រាប់ម្នាក់ៗដាក់ឃ្លាតពីគ្នាចម្ងាយ ២ម៉ែត្រ ក៏ដោយ ក៏ជាទូទៅមិនបំពេញទៅនឹងលក្ខខណ្ឌ "នៅផ្ទះ" និង "រក្សាគម្លាតពីគ្នា" នោះទេ។ លក្ខណៈនៃការប្រើប្រាស់រួមគ្នានូវសម្ភារបរិក្ខារបែបនេះ អាចនាំឲ្យមានការរីករាលដាលនៃមេរោគទៅវិញទេ។ ទោះជាយ៉ាងណា មុននឹងការបិទការប្រើប្រាស់ទីកន្លែងប្រភេទនេះ ទីកន្លែងស្នាក់នៅជំនួសផ្សេងដែលសមស្របត្រូវរកឲ្យបានសម្រាប់ផ្តល់ដល់អ្នករស់នៅនៃទីតាំងនោះ។ ដរាបណា ជម្រកស្នាក់នៅគ្រាអាសន្ននៅតែបើកដំណើរការ ត្រូវខិតខំប្រឹងប្រែងធ្វើយ៉ាងណាឲ្យអ្នករស់នៅ អ្នកធ្វើការ ឬអ្នកមកទស្សនកិច្ចនៅទីកន្លែងនោះមានសុវត្ថិភាព តាមរយៈការអនុវត្តវិធានការអនាម័យ និងការផ្តល់ឧបករណ៍បរិក្ខារការពារខ្លួន។ ចំពោះអ្នកដែលរស់នៅក្នុងជម្រកស្នាក់នៅ ដែលបានធ្វើតេស្តវិជ្ជមានមេរោគកូរ៉ូណា ជម្រើសចត្តាឡីស័កដោយមាននូវសេវាគាំពារចាំបាច់នានា ត្រូវតែរៀបចំឲ្យមានឡើង។

១១. ធានាថា ធនាគារស្បៀងអាហារ និងសេវាគាំពារផ្សេងៗសម្រាប់ប្រជាជនគ្មានផ្ទះសម្បែង ត្រូវបានគេបញ្ចូលក្នុងបញ្ជីនៃអ្នកផ្គត់ផ្គង់សេវាចាំបាច់នានា និងត្រូវបានអនុញ្ញាតឲ្យបន្ត និងពង្រីកសេវាក្នុងអំឡុងនៃការបិទប្រទេស។ រដ្ឋាភិបាល ត្រូវតែធានាថា អ្នកផ្គត់ផ្គង់សេវាទាំងនេះ អាចទទួលបានព័ត៌មានសុខភាពដែលបានធ្វើបច្ចុប្បន្នភាព ម៉ាស ទឹកលាងសម្អាតដៃ និងឧបករណ៍បរិក្ខារការពារខ្លួនចាំបាច់ផ្សេងៗ ដើម្បីបន្តការផ្តល់សេវាគាំពារទាំងនោះដោយសុវត្ថិភាព។

១២. ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគកូវីដ-១៩ តាមរយៈសេវាគាំទ្រ ឬធនាគារស្បៀងអាហារសម្រាប់អ្នកគ្មានផ្ទះសម្បែង អនុសាសន៍របស់អង្គការសុខភាពពិភពលោកស្តីពីអនាម័យ និងការរក្សាគម្លាតសុវត្ថិភាព គួរតែដាក់ឲ្យអនុវត្តយ៉ាងទូលំទូលាយតាមដែលអាចធ្វើបាន និងការផ្តល់សេវានានាកាន់តែមានលក្ខណៈវិមជ្ឈការឡើង ដោយរួមទាំងគិតគូរពិចារណាអំពីការគាំទ្រដល់ ទីតាំង ឬការផ្តល់សេវាដល់ "ផ្ទះ"។ ការផ្តាច់សេវាចាំបាច់សម្រាប់បុគ្គលដែលស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ឬក្នុងស្ថានភាពគ្មានផ្ទះសម្បែងដោយគ្មានផ្តល់នូវទម្រង់ផ្សេងនៃការគាំទ្រជាការរំលោភដល់កាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ រួមមានសិទ្ធិមានម្ហូបអាហារ និងសិទ្ធិទទួលបានបទដ្ឋានជីវភាពរស់នៅសមរម្យ។ ការការពារដ៏សំខាន់ដែលផ្តល់ដោយសិទ្ធិទាំងនេះ មិនអាចជាកម្មវត្ថុនៃការលើកលែងដែលអនុញ្ញាតបាននោះទេ បើទោះបីជាមានការប្រកាសដាក់រដ្ឋក្នុងគ្រាអាសន្នក៏ដោយ។

១៣. រដ្ឋាភិបាល ត្រូវតែមិនអនុវត្តវិធានការណាដែលអាចបណ្តាលឲ្យប្រជាជនក្លាយជាជនគ្មានផ្ទះសម្បែង ដូចជា ការបណ្តេញចេញជាដើម។ ការបណ្តេញចេញ អាចអនុញ្ញាតឲ្យធ្វើទៅបានតែក្នុងករណីចាំបាច់ ដើម្បីការពារអ្នករស់នៅតាមផ្ទះ ពីមហន្តរាយដែលមានក្នុងផ្ទះនោះតែប៉ុណ្ណោះ ហើយអ្នកដែលត្រូវគេបណ្តេញចេញត្រូវបានគេផ្តល់ឲ្យនូវទីកន្លែងស្នាក់នៅជំនួស។

១៤. ធានាឲ្យមានការទទួលបានយុត្តិធម៌សម្រាប់បុគ្គលទាំងឡាយ គ្រួសារ ឬសហគមន៍នានាដែលកំពុងជួបប្រទះភាពគ្មានផ្ទះសម្បែង ឬដែលត្រូវគេបណ្តេញចេញដែលនាំឲ្យគ្មានផ្ទះសម្បែង ហើយដែលពួកគេកំពុងស្វែងរកការដោះស្រាយប្រកបដោយប្រសិទ្ធភាព។